**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៣៨.០២៦.០០១.ស.ជ.ណ

# សេចក្តីជូនដំណឹង

បន្ទាប់ពីធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីណែនាំ លេខ ធ៣៧-០២៥-០២៧ សកណន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ស្តីពី វិធានការជួយសម្រាលបន្ទុកដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ ធនាគារជាតិនៃកម្ពុជាបានសង្កេតឃើញថា ការដាក់ពាក្យស្នើសុំការលើកលែងពាក់ព័ន្ធនឹងការទូទាត់សងឥណទានពីអតិថិជនដែលជាយោធិននិងជាជនភៀសសឹក មានការកើនឡើងកាន់តែច្រើន ដែលជាហេតុធ្វើឱ្យដំណើរការនៃការសម្របសម្រួលសំណើទាំងនោះមានការយឺតយ៉ាវពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ ដើម្បីលើកទឹកចិត្តដល់យោធិនជួរមុខ ដែលបំពេញបេសកកម្មការពារបូរណភាពទឹកដីក្នុងសមរភូមិប្រយុទ្ធ ធនាគារជាតិនៃកម្ពុជាស្នើសុំការអនុគ្រោះពីបងប្អូនជនភៀសសឹកទាំងអស់ ដោយផ្តល់អាទិភាពសម្របសម្រួលសំណើរបស់យោធិនជួរមុខ ជាមុនសិន។ ទន្ទឹមនេះ សម្រាប់យោធិនជួរមុខដែលបានដាក់ពាក្យស្នើសុំការលើកលែងរួចរាល់ ប៉ុន្តែមិនទាន់ទទួលបានការឆ្លើយតបពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សូមទាក់ទងមកលេខទូរសព្ទហាត់ឡាញរបស់ធនាគារជាតិនៃកម្ពុជាទីស្នាក់ការកណ្តាលដែលមានលេខ ០៨៥ ៦០០ ០០២/ ០៨៥ ៦០០ ០០៣/ ០៩៨ ២២០ ០០១/ ០៩៨ ២២០ ០០២ និង ០៩៧ ២៧៨ ៣០៣០។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគីពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

*ថ្ងៃព្រហស្បតិ៍ ១៣កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦*

**ទំនាក់ទំនង៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

(៨៥៥) ២៣ ៩៨០ ១៨៨
nbccommunications@nbc.gov.kh | www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_